ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម

**សេចក្ដីជូនដំណឹង**

**ស្ដីពី**

**ការទប់ស្កាត់ករណីឆបោកសមាជិក ប.ស.ស. តាមរយៈការបង់ភាគទានរបបសន្តិសុខសង្គម មកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

បេឡាជាតិសន្តិសុខសង្គម ( **ប.ស.ស.** ) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជម្រាបជូន **លោក លោកស្រីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន សាធារណជន និងសមាជិក ប.ស.ស.** ឱ្យបានជ្រាបថា នាពេលថ្មីៗនេះ មានករណីឆបោកសមាជិក **ប.ស.ស.** តាមប្រព័ន្ធអនឡាញ ដោយការបន្លំខ្លួនជាមន្ត្រី **ប.ស.ស.** ប្រើប្រាស់រូបថត និងនិមិត្តសញ្ញា **ប.ស.ស.** ឬក្លែងបន្លំលិខិតជូនដំណឹងបង់ភាគទាន ដោយប្តូរលេខគណនីធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ទៅជាលេខគណនីធនាគារ ឬ QR Code ផ្ទេរប្រាក់គណនីផ្ទាល់ខ្លួន និងបានទាក់ទងទៅកាន់សមាជិក ដោយផ្ទាល់តាមតេឡេក្រាម ឬប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ដើម្បីណែនាំឱ្យរដ្ឋបាលសហគ្រាស គ្រឹះស្ថាន និងសមាជិក **ប.ស.ស.** ធ្វើការបង់ភាគទានតាមលេខគណនី ឬ QR Code ក្លែងបន្លំនោះ។

ក្នុងន័យនេះ **ប.ស.ស.** នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ជូន ដូចខាងក្រោម៖

១. **ប.ស.ស.** មិនមានគោលការណ៍ឱ្យម្ចាស់សហគ្រាស គ្រឹះស្ថាន និងសមាជិក **ប.ស.ស.** បង់ភាគទានទៅគណនីដែលមានឈ្មោះផ្ទាល់ខ្លួនរបស់ជនណាម្នាក់ឡើយ។

២. ការបង់ភាគទានតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក **ប.ស.ស.** ត្រូវអនុវត្តតាមរយៈមុខងារបង់ប្រាក់លើកម្មវិធីទូរសព្ទដៃរបស់ធនាគារដៃគូចំនួន៤ រួមមាន៖ ធនាគារ CANADIA, ACLEDA, ABA និង FTB) ឬអញ្ជើញទៅកាន់ធនាគារដៃគូដោយផ្ទាល់។

៣. ការបង់ភាគទានតាមរបបភាគទានជាកាតព្វកិច្ចរបស់សហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តតាមរយៈមុខងារបង់ប្រាក់លើកម្មវិធីទូរសព្ទដៃរបស់ធនាគារដៃគូ **ប.ស.ស.** ឬលេខគណនី **ប.ស.ស.** នៅធនាគារដៃគូទាំង១១ ដែលមាននៅក្នុងសេចក្តីជូនដំណឹងលេខ០១១/២៥ ប.ស.ស. ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥ ឬអញ្ជើញទៅកាន់ធនាគារដៃគូដោយផ្ទាល់។

៤. **ប.ស.ស.** បាននិងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្រាវជ្រាវ រកមុខជនឆបោក ដើម្បីនាំយកមកទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៥. ករណីសង្ស័យ ឬត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមក Call Center លេខ ១២៨៦ ឬ ១២៩៧ ឬក្រុមតេឡេក្រាម "បេឡាជាតិសន្តិសុខសង្គម_Chat" https://t.me/nssfcambodia_Chat ឬ "ប្រអប់បណ្តឹងអនាមិក" https://feedback.mlvt.gov.kh/feedback ដើម្បីដាក់ពាក្យបណ្តឹង។

អាស្រ័យហេតុនេះ សូម លោក លោកស្រីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន សាធារណជន និងសមាជិក **ប.ស.ស.** មេត្តាជ្រាបជាព័ត៌មាន និងសូមបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះករណីឆបោកខាងលើនេះ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

អាសយដ្ឋាន អាគារទីស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ , ០២៣ ៩៩ ៥២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh